# INTERNATIONAL HUMAN RIGHTS DAY 2004

**Speech by**

**Dr. Kek Galabru,**
**Chairperson for CHRAC**

**THE CAMBODIAN HUMAN RIGHTS ACTION COMMITTEE (CHRAC)**
A coalition of 18 local NGOs working on human rights issues in Cambodia

**December 2004**

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ–សមាគមការពារសិទ្ធិមនុស្សកម្ពុជា

**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**

ADHOC - CCPCR - CDP - CHHRA - CWCC - GENEROUS - IDA - KID - KHMER CHAM ISLAM - KKKHRA – KKKHRDA - KSA - KYA - LAC - LICADHO – OUTREACH - TASK FORCE - VIGILANCE

# ព្រះករុណា ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

## ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈ !

តាងនាមឱ្យអង្គការនានា ខ្ញុំម្ចាស់ និងកូនចៅរបស់ព្រះអង្គទាំងអស់គ្នា ជួបប្រជុំគ្នាថ្ងៃនេះ សូមថ្លែងអំណរអរព្រះករុណាទិគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះព្រះរាជានុញ្ញាតប្រទានឱ្យកូនចៅរបស់ព្រះអង្គទាំងអស់គ្នា ចូលថ្វាយបង្គំគាល់ព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទិវាសិទ្ធិមនុស្សអន្តរជាតិដ៏មហោឡារិកនៅពេលនេះ ។

ព្រះករុណាអម្ចាស់ជីវិតតម្កល់លើត្បូង ថ្ងៃទី ១០ ធ្នូ គឺជាថ្ងៃដែលមហាសន្និបាតនៃអង្គការសហប្រជាជាតិ បានអនុម័តសេចក្ដីប្រកាសជាសកលនៃសិទ្ធិមនុស្ស កាលពីឆ្នាំ១៩៤៨ នៅទីក្រុងប៉ារីស ដោយបានប្រកាសសិទ្ធិមនុស្សជាមូលដ្ឋានសំរាប់ជនគ្រប់រូប ។ ពិធីប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិឆ្នាំ២០០៤នេះ អង្គការយូណេស្កូ និងឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានឧទ្ទិសទិវាថ្ងៃនេះជាប្រធានបទនៃការអប់រំសិទ្ធិមនុស្ស ។ អង្គការ-សមាគមនានាកម្ពុជាជាច្រើនបានជួបជុំគ្នា ជាសកម្មជនអប់រំសិទ្ធិមនុស្សផ្ទាល់សំរាប់ប្រជារាស្ត្រកម្ពុជា ព្រមទាំងផ្ដល់ជំនួយសង្គ្រោះជូនជនរងគ្រោះពីករណីរំលោភសិទ្ធិមនុស្ស ។

ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីគោរពសក្ការៈ កូនចៅរបស់ព្រះអង្គទាំងអស់គ្នា និងខ្ញុំម្ចាស់ បានដឹងនិងឃើញយ៉ាងច្បាស់ ពីព្រះរាជបូជនកិច្ច ព្រះរាជហឫទ័យគាំទ្រយ៉ាងខ្លាំងក្លាជាមួយអង្គការយូណេស្កូលើគោលការណ៍លើកស្ទួយខាងវិស័យអប់រំសិទ្ធិមនុស្ស ។ កូនចៅរបស់ព្រះអង្គទាំងអស់គ្នា និងខ្ញុំម្ចាស់មានមោទនភាព និងទទួលបាននូវមហាកិត្តិយសយ៉ាងកក់ក្ដៅក្រៃលែង ចំពោះព្រះរាជានុញ្ញាតឱ្យចូលគាល់ និងថ្វាយនូវការគាំទ្របន្តព្រះបូជនកិច្ចក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្សនៅកម្ពុជា ។

ព្រះរាជាណាចក្រកម្ពុជាកំពុងតែប្រឈមមុខជាមួយបញ្ហាសិទ្ធិមនុស្សច្រើនបែបយ៉ាង កូនចៅរបស់ព្រះអង្គទាំងអស់គ្នា សូមថ្លែងនូវអំណរអរព្រះគុណយ៉ាងក្រៃលែងនូវព្រះគតិបណ្ឌិត

ណែនាំប្រជារាស្ត្រខ្មែរនិងរាជរដ្ឋាភិបាលកម្ពុជា ព្រោះយើងទាំងអស់គ្នាកំពុងប្រឈមមុខដោះស្រាយបញ្ហាទាំងនេះយ៉ាងខ្លាំងក្លា ។

ជាពិសេស កូនចៅរបស់ព្រះអង្គទាំងអស់គ្នា សូមព្រះករុណាព្រះអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះរាជាអនុញ្ញាតទូលថ្វាយនូវវិបត្តិនៃនីតិរដ្ឋ ដូចជា ប្រព័ន្ធច្បាប់ប្រឈមនឹងឧបសគ្គរារាំងជាច្រើនចំពោះបញ្ហាធ្ងន់ធ្ងរនានានៅព្រះរាជាណាចក្រកម្ពុជា រួមមានករណីលួចបន្លំយកដីធ្លី ករណីរំលោភសេពសន្ថវៈ និងការបំពាបំពានផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ កាជួញដូរមនុស្ស និងអំពើពុករលួយ ។ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះឱ្យមាន ប្រសិទ្ធិភាព គឺចាំបាច់ត្រូវពង្រឹងនីតិរដ្ឋនៅកម្ពុជា ដោយធានាថា ច្បាប់រដ្ឋត្រូវបានគោរពពី បណ្តាជនគ្រប់រូប ដូច្នេះជនដែលប្រព្រឹត្តបទល្មើសមិនត្រូវបានរួចខ្លួនពីការផ្តន្ទាទោសតាមផ្លូវ ច្បាប់ឡើយ ។ ការពង្រឹងនីតិរដ្ឋ គឺជាអាយុជីវិតក្នុងវិភាគទានលើកិច្ចអភិវឌ្ឍន៍សង្គមកម្ពុជា ដើម្បីឈានទៅរកការកាត់បន្ថយភាពក្រីក្រ និងធានាបាននូវកិច្ចការពារជីវភាពរស់នៅល្អប្រសើរសំរាប់ប្រជារាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាគ្រប់រូប ។ កូនចៅរបស់ព្រះអង្គទាំងអស់គ្នា មានភាពជឿជាក់ថា នីតិរដ្ឋអាចធ្វើឱ្យប្រសើរឡើងបាននៅកម្ពុជា តាមរយៈកំណែទម្រង់យ៉ាងច្បាស់លាស់នូវគោលការណ៍ដែលមានស្រាប់នៃស្ថាប័នយុត្តាធិការ និង តុលាការគ្រប់លំដាប់ ការផ្តួចផ្តើមឱ្យមានស្ថាប័នឯករាជ្យថ្មីៗ និងការលប់បំបាត់អំពើពុករលួយ ព្រមទាំងលើកកំពស់វិជ្ជាជីវៈតាមបទដ្ឋាននៃក្រមសីលធម៌ ដោយមនុស្សគ្រប់រូប និងស្ថាប័នដែលពាក់ព័ន្ធក្នុងការជួយគាំទ្រវិស័យច្បាប់កម្ពុជា ។ កូនចៅរបស់ព្រះអង្គទាំងអស់គ្នា ដោយរួមនឹងកម្លាំងសុចន្ទះ ព្រមទាំងកិច្ចប្រឹងប្រែងនៃស្ថាប័នជាតិ និងពីគ្រប់ផ្នែកទាំងអស់នៃសង្គមអាចរួមគ្នាឈានទៅរកភាពជោគជ័យបាន ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ក្នុងទិវាដ៏វិសេសវិសាលនេះ ខ្ញុំម្ចាស់ សូមក្រាបបង្គំទូលថ្វាយនូវជនរងគ្រោះ ១០ នាក់ ដែលតំណាងឱ្យជនរងគ្រោះបួនក្រុមនៃប្រជារាស្ត្រកម្ពុជាដែលបានទទួលរងគ្រោះពីការរំលោភសិទ្ធិមនុស្ស ។ លោក-អ្នកស្រី និងកុមារីតំណាងឱ្យជនរងគ្រោះទាំងអស់នេះបានស្ម័គ្រចិត្តធ្វើដំណើរមកថ្ងៃនេះ ដើម្បីថ្វាយបង្គំចូលគាល់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងបង្គំទូលថ្វាយបញ្ជាក់នូវបញ្ហាសំខាន់ៗ ៤ បែប ដែលកំពុងតែប្រឈមមុខដោះស្រាយ : ការរំលោភយកដីធ្លី អំពើហិង្សាក្នុងគ្រួសារ ការរឹតបន្តឹងសេរីភាពនៃការបញ្ចេញមតិ-សេរីភាពនៃការរួបរួមប្រជុំ និងករណីក្មេងដែលរងគ្រោះ

ដោយអំពើរំលោភសេពសន្ថវៈក្នុងប្រទេសកម្ពុជា ។ រាល់បញ្ហាទាំងនេះ គឺជាកង្វល់យ៉ាងធំធេងចំពោះកូនចៅរបស់ព្រះអង្គទាំងអស់គ្នា ដែលកំពុងតែប្រឈមមុខនៅសព្វថ្ងៃនេះ ។ កូនចៅរបស់ព្រះអង្គទាំងអស់គ្នា សូមថ្លែងអំណរព្រះគុណព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ដែលព្រះរាជាអនុញ្ញាឱ្យចូលគាល់ថ្វាយបង្គំជួបព្រះភក្រ្តផ្ទាល់នាពេលនេះ។

ជាថ្មីម្តងទៀត ខ្ញុំម្ចាស់សូមអរព្រះគុណយ៉ាងជ្រាលជ្រៅចំពោះព្រះករុណាជាអម្ចាស់ព្រះរាជទានសណ្តោសប្រណីឱ្យមានពិធីសវនាការក្នុងទិវាដ៏មហោឡារិកនេះ និងព្រះបូជនកិច្ចបន្តកិច្ចគាំទ្រសិទ្ធិមនុស្សនៅកម្ពុជា ។ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រះករុណា ព្រះអង្គត្រូវបានថ្វាយភាពទទួលខុសត្រូវក្នុងការធានាការគោរពសិទ្ធិ និងសេរីភាពដល់ប្រជារាស្ត្រគ្រប់រូប ។ កូនចៅរបស់ព្រះអង្គទាំងអស់គ្នា សូមព្រះរាជានុញ្ញាតថ្វាយព្រះពរ សូមព្រះអង្គទទួលបានជោគជ័យនូវព្រះរាជបូជនកិច្ចបន្តការគាំទ្រលើកកំពស់វិស័យសិទ្ធិមនុស្សនៅកម្ពុជា ។

ជាទីបញ្ចប់ ខ្ញុំម្ចាស់សូមបួងសួងដល់ព្រះបារមីនៃព្រះរតនៈត្រ័យ វត្ថុស័ក្តសិទ្ធិក្នុងលោក និងផលានិសង្សនៃកុសលធម៌ទាំងឡាយប្រទានព្រះពរព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង សម្តេចឪ និងសម្តេចម៉ែ សូមមានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ជាម្លប់ដ៏ត្រជាក់ដល់កូនចៅ-ចៅទួតរបស់ព្រះអង្គជារៀងរហូតតទៅ ។

សូមជូនពរដល់ភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ សូមជួបនូវពរទាំងប្រាំប្រការ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភានៈ កុំបីឃ្លាងឃ្លាតឡើយ ។

សូមអរព្រះគុណ និង សូមអរគុណ ។